# ការសាកសួរបានប្រព្រឹត្តទៅទទួលលទ្ធផលច្រើន បើទោះជាសាក្សីមិនសូវជាមានការចងចាំ

*ដោយ ខេលលី ឌុយប្រី អេនគ្រូ*

*ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ និត្យ ធរន្តារាណ*

នៅថ្ងៃពុធ ទី៦ មិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បន្តការធ្វើសក្ខីកម្មរបស់សាក្សី សៅ សារុន លើសំណុំរឿង០០២ប្រឆាំងនឹងជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន។ ទោះបីជា វ័យរបស់សាក្សីធ្វើឲ្យមានការលំបាកខ្លះទៅលើពេលសាកសួរ តែគាត់បានប្រឹងប្រែងអត់ធ្មត់ និងសហការយ៉ាងពេញចិត្តពេញមួយថ្ងៃពេញ។

សវនាការពេលព្រឹក មានការចូលរួមយ៉ាងច្រើនពីសំណាក់អ្នកភូមិដែលមកពីខេត្តតាកែវ និងសិស្សានុសិស្សនៅពេលរសៀល។ សវនាការកាលពីថ្ងៃចន្ទ និងអង្គារ កន្លងទៅនេះពុំមានវត្តមានរបស់សិស្ស និស្សិតចូលរួមនោះទេ ប៉ុន្តែមានវត្តមានយ៉ាងច្រើនពីសំណាក់បងប្អូនអ្នកភូមិ និងប្រជាជន។ នៅថ្ងៃពុធនេះ មានសិស្ស២០០នាក់ មកពីវិទ្យាល័យពងទឹក បានចុះពីរថយន្តក្រុងសំដៅមកបរិវេណនៃអ.វ.ត.ក។ ថ្វីបើពួកគេមិនបានរៀននៅក្នុងថ្នាក់ ហើយមកចូលរួមស្តាប់សវនាការ ប៉ុន្តែពួកគេមានការយល់ដឹងច្រើនអំពីតុលាការនៅថ្ងៃនេះ។ ខុសប្លែកពីសប្តាហ៍មុន និងពាក់កណ្តាលនៃដំណើរការនីតិវិធីពិភាក្សានៅថ្ងៃនេះ ចាប់ផ្តើមពីទស្សនៈសង្ខេបនៃគោលនយោបាយរបស់ខ្មែរក្រហម រហូតទៅដល់អំពើឃោរឃៅដែលកើតមានចំពោះប្រជាជនកម្ពុជា នៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

## សាក្សីវ័យចំណាស់រំឭកឡើងវិញអំពីការចងចាំរបស់គាត់

បន្ទាប់ពីអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី ចូលរួមតាមដានសវនាការពីបន្ទប់ឃុំឃាំងរបស់ខ្លួន។ ប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាលោក សេង ប៊ុនឃាង។

លោក ប៊ុនឃាង ចាប់ផ្តើមតាំងសំណួររបស់គាត់ដោយសួរថា តើលោកសាក្សីធ្លាប់បានចូលរួមក្នុងការប្រជុំណាមួយនៅខេត្តកំពត់ធំ ក្នុងឆ្នាំ១៩៧២ដែរឬទេ? លោក សារុន ឆ្លើយតបថា គាត់អត់ធ្លាប់បានចូលរួមទេ។ ដើម្បីធ្វើឲ្យនឹកឃើញឡើងវិញទាំងស្រុង វាក៏តម្រូវឲ្យមានការដាក់សំណួរទៅសាក្សីមុនសិនដែរ។ លោក ប៊ុនឃាង អានជូនតុលាការពីចម្លើយរបស់សាក្សី នៅអំឡុងពេលសម្ភាស

នៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ។ នៅក្នុងចម្លើយនេះ លោក សៅ សារុន និយាយថានៅឆ្នាំ១៩៧៣ គាត់ធ្លាប់បានចូលរួមប្រជុំនៅខេត្តកំពង់ធំ ដែលមាន គី, ស្វាយ និង ចាំ ។ ដោយពុំនូវចម្លើយកាលពីមុនរបស់គាត់ឆ្លើយទៅកាន់ ក.ស.ច.ស សាក្សីនឹកឃើញវិញ ព្រមទាំងបានប្រាប់ថា ខ្លួនពិតជាបានចូលរួមក្នុងការប្រជុំនៅមែន និងបានបញ្ជាក់ទៀតថា ប៉ុល ពត ក៏មានវត្តមាននៅពេលនោះដែរ ។

លោក ប៊ុនយាង បានជម្រាបទៅសាក្សីថា គាត់ក៏បាននិយាយថា ជនជាប់ចោទ នួន ជា ក៏មានវត្តមាននៅការប្រជុំនោះដែរ ។ លោក សៅ សារុន និយាយថាវាពិតជាត្រឹមត្រូវមែន ។ សាក្សីបាននឹកឃើញទៀតថា មានអ្នកតំណាងដែលមកពីបណ្តាខេត្តផ្សេងៗបានចូលរួមក្នុងកិច្ចប្រជុំនេះដែរ ប៉ុន្តែគាត់នឹកមិនឃើញឈ្មោះណាមួយឡើយ ហើយក៏មិនចាំថាមានមនុស្សចំនួនប៉ុន្មាននាក់ទេ ដែលមកចូលរួម ប៉ុន្តែលោកគ្រាន់តែចាំថា កិច្ចប្រជុំនេះមានរយៈពេលយូរប្រហែលជិត១០ថ្ងៃ ។

ដោយសាកសួរពីការចូលរួមរបស់មេដឹកនាំបក្ស លោក ប៊ុនយាង សួរទៅសាក្សីថាតើមានអ្នកដឹកនាំណាផ្សេងទេ ដែលផ្តល់បទបង្ហាញក្រៅពី ប៉ុល ពត ដែរឬទេ? សាក្សី ឆ្លើយតបថា គាត់មិនចាំទេ ។ ដើម្បីរំឭកការចងចាំរបស់គាត់ឡើងវិញម្តងទៀត លោក ប៊ុនយាង បានអាននូវឯកសារចម្លើយរបស់សាក្សីផ្សេងទៀតនៅក្នុងកិច្ចសម្ភាសជាមួយនឹង ក.ស.ច.ស ថា “នួន ជា ជាអ្នកផ្តល់បទបង្ហាញទាក់ទងនឹងនយោបាយរំដោះក្រពត្តិអាមេរិក” ។ “តើពិតជាអញ្ចឹងទេ?” ។ សាក្សីឆ្លើយថាពិតជាអញ្ចឹងមែន ។ លោក ប៊ុនយាង សួរសាក្សីថា តើលោកអាចរៀបរាប់ពីអ្វីដែល នួន ជា និយាយពីខាងលើនោះបានទេ ប៉ុន្តែ សៅ សារុន តបវិញថា “ពុំនិយាយតែរឿងរំដោះជាតិប៉ុណ្ណឹងឯង ។”

សៅ សារុន និយាយថាគាត់មិនដែលស្គាល់ ខៀវ សំផន និងមិនដែលជួបសោះរហូតដល់ក្រោយរំដោះភ្នំពេញ ខែមេសា ឆ្នាំ១៩៧៥ ។

លោក ប៊ុនយាង បន្តទៅសំណួរផ្សេងទៀត ដោយសួរទៅសាក្សីអំពីការតាំងលំនៅថ្មី នៅស្រុកកោះញែក ដែលគាត់បានលើកឡើងកាលពីថ្ងៃមុន ។ សាក្សី សារុន បានលើកឡើងថា “វាមានការលំបាក និងខ្វះខាតដីស្រែនៅតាមព្រំដែន ដូច្នេះប្រជាជនក៏រើចេញទៅ” ។ គាត់មិនបានដឹងពីមូលហេតុច្បាស់លាស់នៃការរើចេញទៅនោះទេ ប៉ុន្តែអ្វីដែលគាត់ដឹង គឺគាត់បាននិយាយថា “វាមានដីដែលទំនេរតិចនៅក្នុងស្រុកកោះញែកនេះ ។” ការរើលំនៅរបស់ប្រជាជនដែលមកពីស្រុកកោះញែក ទៅខេត្តមណ្ឌលគិរី គឺនៅក្នុងអំឡុងឆ្នាំ១៩៧៦ ឬ១៩៧៧ តែគាត់បានបញ្ជាក់ថា សហករណ៍មិនទាន់បង្កើតនៅឡើយទេរហូតដល់ឆ្នាំ១៩៧៧ ។

ទាក់ទងទៅនឹងស្ថានភាពរស់នៅរបស់ប្រជាជន សៅ សារុន បានលើកឡើងថា ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ប្រជាជនហូបដោយឡែកពីគ្នា តែក្រោយពីឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧ប្រជាជនហូប «រួមគ្នា» ដោយក្នុងមួយក្រុមមានមនុស្ស២០ ឬ៣០នាក់។ សួរថាតើពេលហ្នឹងមានបង្កើតជា «ក្រុមប្រវាស់ដៃ» ឬនៅ? សាក្សីនិយាយថា មុនឆ្នាំ១៩៧៥ មាន «ប្រភេទក្រុមសាមគ្គីដើម្បីជួយគ្នា។»

បន្តទៅប្រធានបទនៃការជម្លៀសដោយបង្ខំ លោក ប៊ុនយាង សួរទៅកាន់សាក្សីថា តើនៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ លោកនៅឯណា? សៅ សារុន ឆ្លើយថា គាត់នៅស្រុកពេជ្រចិន្ដា ហើយក៏មិនបានដឹងពីផែនការនៃការជម្លៀសប្រជាជនចេញពីទីក្រុង ដូច្នេះក៏មិនមានការជម្លៀសទៅស្រុកពេជ្រចិន្ដាទេនៅពេលនោះ។ លោកបានជម្រាបទៅតុលាការថា គាត់មិនដែល ឮពាក្យថា «ប្រជាជនថ្មី» ពីមុនមកទេ។

ដោយសារតែសាក្សីបានប្រាប់ទៅអង្គសវនាការថា ខ្លួនធ្លាប់ជាលេខាស្រុកពេជ្រចិន្ដា ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៨។ លោក ប៊ុនយាង បានសួរទៅសាក្សីថា តើគាត់មានកត់សម្គាល់ឃើញថា «មានអ្វីផ្លាស់ប្ដូរ» នៅក្នុងការត្រួតត្រារបស់លោក បន្ទាប់ពីឆ្នាំ១៩៧៥ដែរឬទេ? សៅ សារុន បានឆ្លើយតបថា ក្នុងនាមគាត់ជាលេខា គាត់បានកត់សម្គាល់ឃើញថា គ្មានអ្វីផ្លាស់ប្ដូរទេ។

បន្តដោយការតាំងសំណួរអំពីប្រព័ន្ធរាយការណ៍រវាងថ្នាក់ស្រុក និងថ្នាក់តំបន់ សាក្សីបានពន្យល់ថា ក្នុងនាទីជាលេខាស្រុក គាត់បានរាយការណ៍ទៅថ្នាក់តំបន់អំពី «បញ្ហាដាំដុះស្រែ និងបង្កបង្កើនផល» មួយសប្ដាហ៍ម្ដង។

លោក ប៊ុនយាង សួរទៅកាន់សាក្សីថា តើគាត់«មានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យចាប់ខ្លួននរណាម្នាក់ដែរឬទេ?» សៅ សារុន ឆ្លើយដោយម៉ឺងម៉ាត់ថា «ទេ! ខ្ញុំមិនមានសិទ្ធិទេ។ ក្នុងនាទីជាលេខាស្រុកពេជ្រចិន្ដា ខ្ញុំមិនដែលបញ្ជាឲ្យចាប់ខ្លួនជនណាម្នាក់ឡើយ។» គាត់ក៏មិនបានដឹងថា តើលេខាតំបន់១០៥មានសិទ្ធិអំណាចដែរឬយ៉ាងណាទេ។

ទាក់ទងទៅនឹងវត្តមានរបស់គាត់ក្នុងការប្រជុំគណៈតំបន់ សាក្សី សៅ សារុន និយាយថា គាត់ទៅក្នុងនាមជាសមាជិកតំបន់ទទួលបន្ទុកខាងសុខាភិបាល។ គាត់បានពន្យល់ថា ការប្រជុំគណៈតំបន់ គឺធម្មតាប្រព្រឹត្តទៅមួយខែម្ដង ឬពីរខែម្ដងនៅមន្ទីរតំបន់។ មានវត្តមានរបស់អ្នកតំណាងគ្រប់ស្រុកនៅតាមតំបន់។ សៅ សារុន បានពន្យល់ទៀតថា ការប្រជុំនេះពាក់ព័ន្ធទៅនឹង «បញ្ហាគ្រប់គ្រងប្រជាជន» និង «បញ្ហាជីវភាព និងសុខុមាលភាពរបស់ប្រជាជន។» និងពិភាក្សាគ្នាអំពីវិធី«ធ្វើឲ្យ»ប្រជាជនផុតពីភាពក្រីក្រ។

បន្ទាប់ពីសំណួរ លោក ប៊ុនយាង បានស្នើលោក សៅ សារុន ឲ្យធ្វើការបកស្រាយពីកិច្ចប្រជុំគណៈស្រុកដែលគាត់បានចូលរួម ។ សាក្សីពន្យល់ថា ក្នុងនាមជាលេខាស្រុកពេជ្រចិន្តា គាត់ដឹកនាំការប្រជុំក្នុងស្រុក នៅពេលដែលមានការណែនាំពីតំបន់ (តំបន់១០៥) ។ ដូចនឹងការប្រជុំថ្នាក់តំបន់ដែរ គឺតាមធម្មតាពួកគេប្រជុំមួយខែម្ដង ឬពីរខែម្ដង និងវត្តមានរបស់អ្នកចូលរួម ដូចជា គណៈលេខារង សមាជិកនៃគណៈស្រុក និងគណៈឃុំប្រចាំស្រុក ។ សាក្សីនិយាយថា តាផាក់ ធ្លាប់ជាអនុលេខាស្រុកពេជ្រចិន្តា ប៉ុន្តែគាត់រកនឹកមិនឃើញ "ឈ្មោះពេញ" របស់ តាផាក់ ជាអ្វីឡើយ ។

សៅ សារុន បន្តទៀតថា គាត់បានទទួលរបាយការណ៍យ៉ាងទៀងទាត់ពីគណៈឃុំ "ជារៀងរាល់ខែ ។" គណៈឃុំសរសេររបាយការណ៍ពីបញ្ហាបង្កបង្កើនស្រូវ និង"ការគ្រប់គ្រងនៅតាមតំបន់របស់ពួកគេ ។" នៅពេលដែលសួរទៅសាក្សីថា គាត់ធ្វើការប៉ុន្មានថ្ងៃក្នុងមួយសប្ដាហ៍ គាត់បានឆ្លើយថា "ខ្ញុំធ្វើការមិនសូវទៀតទាត់ទេ ជួនកាលយើងធ្វើការមួយថ្ងៃ ឬ ពីរថ្ងៃ ក្នុងមួយសប្ដាហ៍ ។"

លោក ប៊ុនយាង បន្តសួរអំពីព័ត៌មានដែលលោក សៅ សារុន បានដឹងពីមន្ទីរ "ក-១១ ។" សាក្សីនិយាយថា គាត់ស្គាល់មន្ទីរ ក-១១ មានន័យថា គាត់ធ្លាប់បានឮពីមន្ទីរនេះ តែគាត់មិនបានដឹងច្បាស់ពីមុខងារ និងតួនាទីរបស់មន្ទីរនេះទេ ។ ប៉ុន្តែគាត់នឹកឃើញថា មន្ទីរនេះមានទីតាំងនៅជិតមន្ទីរតំបន់ ក្នុងភ្នំក្រោម ។ ថ្វីបើនៅក្នុងចម្លើយរបស់សាក្សីថា គាត់ "មិនដែលស្គាល់មន្ទីរក-១១" តែគាត់នឹកឃើញថា មានបុរសម្នាក់ឈ្មោះ សុភា ជាអ្នកទទួលខុសត្រូវនៅទីនោះ ហើយក៏ជាអ្នកទទួលខាងយោធាតំបន់ដែរ ។

បន្ទាប់ពី ក-១១ លោក ប៊ុនយាង សាកសួរថា តើនៅតំបន់១០៥ មានមន្ទីរពាណិជ្ជកម្មដែរទេ? សៅ សារុន ចាំថាមាន ប៉ុន្តែគាត់មិនដឹងពី"លេខកូដ"របស់មន្ទីរនោះទេ ។ ពេលដែលសួរថាតើលោកមាននឹកឃើញពីមន្ទីរ ក-១៦ ទេ គាត់ក៏ចាំដែរថាមន្ទីរ ក-១៦ជា "មន្ទីរដែលទទួលខុសត្រូវខាងសេដ្ឋកិច្ចតំបន់ ។" គាត់បានពន្យល់ថា ដូចជាមន្ទីរ ក-១១ដែរ ក-១៦ មានទីតាំងនៅក្បែរមន្ទីរតំបន់ដែរ ។ ប៉ុន្តែគាត់មិនបានដឹងថា អ្នកណាជាអ្នកទទួលបន្ទុកនៅក្នុងមន្ទីរនេះទេ ។ គាត់បានបញ្ជាក់ថា "ខ្ញុំដឹងត្រឹមតែការងារក្នុងស្រុករបស់ខ្ញុំប៉ុណ្ណោះ" ។

បន្តទៅបញ្ជីនៃមន្ទីរដែលមាននៅក្នុងស្រុក ឬតំបន់របស់សាក្សី លោក ប៊ុនយាង សាកសួរថា តើមាន"មន្ទីរកែប្រ ឬមន្ទីរសន្តិសុខ"នៅក្នុងស្រុកដែរឬទេ? សៅ សារុន ឆ្លើយថា គ្មានមន្ទីរកែប្រែ ឬរៀនសូត្រនៅក្នុងថ្នាក់ស្រុកទេ ប៉ុន្តែវាមាននៅថ្នាក់តំបន់ ។ ដូចជាមន្ទីរពីរដែលមានក-១១ និង ក-១៦ ។ សាក្សីជម្រាបទៅលោក ប៊ុនយាង ថា មន្ទីររៀនសូត្រ គឺស្ថិតនៅជិតមន្ទីរតំបន់ ។ ជាថ្មីម្ដង

ទៀត គឺនៅពេលដែលសាកសួរពីអ្នកណាជាអ្នកទទួលបន្ទុកនៅក្នុងមន្ទីរនេះ លោក សៅ សារុន ឆ្លើយថា «ខ្ញុំមិនដឹងទេ ព្រោះខ្ញុំក្តាប់មិនបានទៅលើកិច្ចការនៅក្នុងថ្នាក់តំបន់ ។»

លោកសហព្រះរាជអាជ្ញាបានប្តូរទៅប្រធានបទផ្សេងមួយទៀត ដែលផ្តោតទៅលើកិច្ចប្រជុំអប់រំនយោបាយរបស់សាក្សី នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ សាក្សីបានលើកឡើងថា «តាមការយល់ដឹងរបស់ខ្ញុំ គោលនយោបាយរបស់បក្ស គឺបង្រួបបង្រួមប្រជាជនឲ្យការពារអធិបតេយ្យភាពទឹកដី និងការពារបូរណភាពជាតិ» ។ គាត់ត្រូវបានអញ្ជើញហៅឲ្យទៅចូលរួមនៅឯភ្នំពេញ ។ ប៉ុន្តែអ្វីដែលគាត់មាននេះគឺបានបាត់បង់ហើយ ដូច្នេះសាក្សីត្រូវការជំនួយខ្លះដើម្បីឲ្យគាត់នឹកឃើញឡើងវិញ ។

ដើម្បីជាជំនួយដល់ការចងចាំរបស់សាក្សី លោក ប៊ុនយាង បានអាននូវចម្លើយផ្សេងទៀតដែលមានក្នុងបទសម្ភាសរបស់លោក សៅ សារុន ជាមួយ ក.ស.ច.ស ដែលថា គាត់បានមកចូលរួមការប្រជុំពីរលើកទៀតនៅភ្នំពេញ មួយគឺនៅបូរីកីឡា និងមួយទៀតនៅឯផ្លូវសហព័ន្ធរុស្សី ។ វិធីនេះធ្វើឲ្យយើងទទួលបានជោគជ័យម្តងទៀត ហើយសាក្សីក៏អាចចាំថា គាត់បានចូលរួមមែន ។

យ៉ាងណាក៏ដោយ សៅ សារុន មិនអាចចាំបានថា អ្នកណាជាអ្នកដឹកនាំវគ្គអប់រំនេះបានទេ ។ ដោយត្រូវការជំនួយម្តងទៀត លោក ប៊ុនយាង បានអាននូវចម្លើយរបស់គាត់នៅពេលដែលគាត់ធ្វើការសម្ភាសជាមួយ ក.ស.ច.ស ។ ចម្លើយមានដូចតទៅ គឺ«នួន ជា បានធ្វើបទបង្ហាញអំពីបញ្ហាសេដ្ឋកិច្ច និងមាគ៌ាសេដ្ឋកិច្ច ។» សាក្សីបានឆ្លើយតបថា «បាទ! វាពិតជាត្រឹមត្រូវគឺគាត់ធ្វើបទបង្ហាញអំពីបញ្ហាសេដ្ឋកិច្ច ។» សួរទៅលើអ្វីដែលលោក នួន ជា បានខ្ទេសនាមមានអ្វីខ្លះ? លោក សៅ សារុន បានប្រាប់ថា «វាទាក់ទងទាំងអស់នឹងការដឹកនាំប្រជាជនឲ្យធ្វើស្រែ ដើម្បីឲ្យប្រជាជនជៀសផុតពីភាពអត់ឃ្លានជាដើម ។»

សម្រាប់ប្រធានបទចុងក្រោយនៃការសាកសួរនេះ លោក ប៊ុនយាង បានសួរទៅសាក្សីពីបញ្ហាប្រជុំស្វ័យទិតៀន ។ សាក្សីនិយាយថា មានការប្រជុំស្វ័យទិតៀននៅក្នុងតំបន់១០៥ ប៉ុន្តែមិនសូវជាមានញឹកញាប់ទេ «ជួនកាល ប្រជុំ៦ខែម្តង» ។ គាត់ពន្យល់ថា «យើងព្យាយាមធ្វើខ្លួនឯងដើម្បីដឹកនាំប្រជាជនឲ្យបានល្អ ។» សៅ សារុន បន្តទៀតថា ក្នុងក្របខណ្ឌស្រុក មានគណៈស្រុក និងអនុគណៈស្រុកដែលចូលរួម ។ ការប្រជុំនេះធ្វើឡើងដោយមានមនុស្ស៨ ទៅ១០នាក់ចូលរួម ។ គោលបំណងនៃការប្រជុំស្វ័យទិតៀននេះគឺ «ដើម្បីឲ្យកម្មាភិបាលល្អ ស្មោះត្រង់ជាមួយនឹងប្រជាជន និងកុំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ។ ប្រសិនបើនរណាម្នាក់មានកំហុស អ្នកនោះត្រូវសារភាពនូវ«ទោសកំហុសរបស់ខ្លួន» ហើយអ្នកដែលបានសារភាពនូវទោសកំហុសរបស់ខ្លួនហ្នឹង មិនត្រូវបានយកទៅរៀនសូត្រទេ ។ «ពួកគេបានត្រឹមទទួលការរិះគន់ ហើយអត់មានអីទេ» ។

បន្ទាប់មកលោក ប៊ុនឃាង បានបញ្ចប់ការសាកសួរ និងសុំការអនុញ្ញាតដើម្បីផ្តល់វេទិកាជូនទៅសហការីអន្តរជាតិ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឪែល លីសាក់ ។ លោកប្រធាន និល ណុន អរគុណទៅលោក ប៊ុនឃាង និងផ្តល់វេទិកាជូនទៅលោក លីសាក់ ។

## “ខ្ញុំរាយការណ៍អ្វីៗគ្រប់យ៉ាងដោយស្មោះអស់ពីចិត្ត”

ដើម្បីស្វែងរកភាពសុក្រឹត្យពីសាក្សី ដែលមានការភ្លេចភ្លាំង លោក លីសាក់ ចាប់ផ្តើមធ្វើការសាកសួរសំនួរមួយដោយត្រង់ថា “តើលោកបានឆ្លើយដោយស្មោះត្រង់ឬទេ នៅពេលដែលលោកផ្តល់ចម្លើយទៅខាងចៅក្រមស៊ើបអង្កេត?”

លោក សារុន ឆ្លើយថា “បាទ! ខ្ញុំពិតជាបានឆ្លើយយ៉ាងត្រង់ ។ ខ្ញុំរាយការណ៍ជូនចំពោះលោកចៅក្រមទាំងអស់ដោយស្មោះអស់ពីចិត្តពីថ្លើមនូវអ្វីដែលខ្ញុំបានដឹង អ្វីដែលខ្ញុំបានឃើញ ខ្ញុំរាយការណ៍ជូនទៅលោកចៅក្រមទាំងអស់ ។”

លោក លីសាក់ សួរទៅសាក្សីថា តើសហចៅក្រមស៊ើបអង្កេតបានអានចម្លើយដោយឮៗ និងច្បាស់ៗឬទេ? លោក សៅ សារុន ប្រាប់ថា “ ដោយសារតែភ្នែកខ្ញុំខ្សោយ ពួកគេបានអានឲ្យខ្ញុំស្តាប់ ។” គាត់បញ្ជាក់ទៀតថា គាត់អានចម្លើយឡើងវិញម្តងទៀត មុនពេលដែលគាត់ចូលមកផ្តល់សក្ខីកម្មនេះ ។ នៅពេលនោះ“ខ្ញុំអត់មានបានស្នើសុំឲ្យកែប្រែនូវចម្លើយណាមួយរបស់ខ្ញុំឡើយ ពីព្រោះពេលដែលខ្ញុំផ្តល់ចម្លើយទៅឲ្យលោកចៅក្រមនោះ គឺវាសុក្រឹត្យ និងច្បាស់លាស់ហើយ ។”

លោក លីសាក់ បានបន្តក្រោយពីទទួលស្គាល់នូវចម្លើយរបស់សាក្សី ដែលគាត់បានធ្វើបទសម្ភាសជាមួយនឹង ក.ស.ច.ស យ៉ាងត្រឹមត្រូវ ។ ដើម្បីឲ្យងាយយល់ថែមទៀត គាត់សួរទៅកាន់សាក្សីលើចម្លើយរបស់គាត់នៅមន្ទីរក-១៦ គឺសួរដោយជាក់លាក់ថា តើមន្ទីរនេះជា“មន្ទីរពាណិជ្ជកម្ម” មែនទេ? សៅ សារុន ឆ្លើយថា “បាទ!” ហើយវាស្ថិតនៅក្រោមការត្រួតត្រារបស់តំបន់១០៥ ។ លោក លីសាក់ សួរទៅសាក្សីដោយបញ្ជាក់នឹងសំនួរនេះថា តើមន្ទីរក-១៦ ជាមន្ទីរពាណិជ្ជកម្ម ឬមន្ទីរតំបន់ ឬក៏វាតែមួយ? សៅ សារុន ឆ្លើយតបម្តងទៀតថា មន្ទីរក-១៦ ជាមន្ទីរតំបន់ ហើយមានប្រវែងប្រហែលជា១០០ម៉ែត្រពីមន្ទីរពាណិជ្ជកម្ម ។

ប្តូរទៅប្រធានបទផ្សេងទៀត លោក លីសាក់ បានសួរទៅកាន់សាក្សីថា តើគាត់បានដឹងពីការបោះពុម្ពផ្សាយ ដែលគេហៅថា ទង់បដិវត្តន៍ ដែរឬទេ? សាក្សីឆ្លើយថា គាត់អត់ចាំពីរឿងបោះពុម្ពផ្សាយនេះទេ គាត់ក៏មិនចាំពីការបោះពុម្ពផ្សាយ“ទង់ក្រហម”នោះដែរ ។ លោក លីសាក់ ក៏ព្យាយាមរំឭកការចងចាំរបស់សាក្សីដែរ ដូចដែលលោក ប៊ុនឃាង បានធ្វើច្រើនដងនៅព្រឹកមិញនេះ ។ ដោយ

បានទទួលការអនុញ្ញាតពីលោកប្រធាន និល ណុន លោកសហព្រះរាជអាជ្ញាបានអានជូនទៅសាក្សីនូវឯកសារចុះថ្ងៃ២៧ សីហា ឆ្នាំ១៩៧៧ ដែលជាសារទូរលេខផ្ញើមកពីលេខាតំបន់១០៥ ឈ្មោះ ឡេង «បញ្ហាទស្សនាវដ្ដីរបស់បក្សនិងទង់បដិវត្តន៍ដែលបានចុះផ្សាយពីឆ្នាំ១៩៧៥-១៩៧៦ ត្រូវបានប្រមូលផ្ដុំទុកដាក់យ៉ាងស្រួលដើម្បីអាន ។» លោក លីសាក់ សួរទៅកាន់សាក្សីថា «តើលោកនឹកឃើញហើយឬនៅថា ឯកសារទង់បដិវត្តន៍នេះបានផ្ញើជូនទៅមន្ទីរស្រុក និងសមាជិកបក្សដើម្បីអានទេ?» សាក្សីអះអាងថា លោកមិនចាំថា លោកបានឃើញនូវឯកសារបោះពុម្ពណាមួយ ដូចជាក្នុងស្រុករបស់គាត់ក៏ដូចជាក្នុងកិច្ចប្រជុំណាមួយដែលគាត់បានចូលរួមនៅឯមន្ទីរតំបន់នោះទេ ។

លោក លីសាក់ ត្រឡប់ទៅពិភាក្សាអំពីការចូលប្រជុំឯភ្នំពេញ ។ សាក្សី សៅ សារុន មិនអាចចាំបានពីទីកន្លែងប្រជុំពិតប្រាកដឡើយ ។ ដើម្បីជាជំនួយដល់ការចងចាំរបស់សាក្សី លោក លីសាក់ អាននូវចម្លើយមួយផ្សេងទៀតពីកិច្ចសម្ភាសរបស់សាក្សីជាមួយ ក.ស.ច.ស ។ ចម្លើយដែលអានគឺ«ដប់ថ្ងៃបន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានទៅចូលរួមប្រជុំនៅសាលាមិត្តភាពខ្មែរ-សូវៀតចំនួន៣ថ្ងៃ ។» សាក្សីឆ្លើយថា «បាទ ! វាពិតជាត្រឹមត្រូវ» ។

លោក ហ្សាស្ដើ ប៉ៅ មេធាវីអន្តរជាតិការពារជនជាប់ចោទ នួន ជា បានធ្វើការជំទាស់មុនគេនៅថ្ងៃនេះ ដោយបានលើកឡើងថា គាត់មិនយល់ស្របទៅលើការតាំងសំនួរសួរទៅសាក្សីរបៀបនេះទេ ។ ជំនួសដោយការអាននូវចម្លើយរបស់សាក្សី និងសួរឲ្យសាក្សីបញ្ជាក់អះអាង យើងគួរតែសួរទៅសាក្សីមុនថា គាត់ចាំអ្វីខ្លះ?

សហព្រះរាជអាជ្ញា លីសាក់ ឆ្លើយតបទៅវិញថា «នេះគឺជាអ្វីដែលខ្ញុំធ្វើ ។ ខ្ញុំបានសួរទៅសាក្សីថា កិច្ចប្រជុំនោះនៅទីណា ។ គាត់ឆ្លើយថា គាត់អត់ចាំទេ អញ្ចឹងបានខ្ញុំអាននូវចម្លើយនោះដើម្បីឲ្យគាត់ចាំឡើងវិញ ។»

លោកប្រធាន និល ណុន ជម្រាបទៅលោក លីសាក់ ថា លោក ប៉ៅ គ្រាន់តែ«ក្រើនរំឭក» គឺមិនមែន«ជំទាស់»ទេ ។ បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានផ្ដល់វេទិកាជូនទៅលោក លីសាក់ បន្តនូវសំណួរ ។

លោកព្រះរាជអាជ្ញាសួរទៅសាក្សីថា បន្ទាប់ពីថ្ងៃរំដោះ រហូតដល់គាត់ស្នើសុំឲ្យមកចូលរួមប្រជុំនៅក្រុងភ្នំពេញ តើលោកចំណាយអស់រយៈពេលប៉ុន្មានដែរ? សាក្សីមិនអាចចាំនូវរយៈពេលពិតប្រាកដទេ តែគាត់និយាយថា វាមិនសូវជាយូរប៉ុន្មានទេ បន្ទាប់ពីរំដោះនោះ ។ សួរថា តើនរណាខ្លះដែលមកប្រជុំជាមួយគាត់? សៅ សារុន ឆ្លើយថា មានមនុស្សបីនាក់ គឺរូបគាត់ម្នាក់បុរសម្នាក់ទៀតឈ្មោះ លក ហើយម្នាក់ទៀតគាត់នឹកមិនឃើញទេ ។

សៅ សារុន ពន្យល់ថា គាត់មិនបានឃើញអ្នកជម្លៀសណាម្នាក់នៅតាមផ្លូវទេ ពេលដែលគាត់ធ្វើដំណើរទៅភ្នំពេញដើម្បីចូលរួមប្រជុំនោះ ពីព្រោះគាត់ធ្វើដំណើរតាមផ្លូវទឹក ។ គាត់បានឲ្យដឹងថា "ខ្ញុំជិះកាណូតពីខេត្តក្រចេះ រហូតមកដល់ភ្នំពេញ" ។ គាត់មកពីខេត្តមណ្ឌលគិរី មកក្រចេះ តាមឡាន ក៏គាត់មិនបានឃើញអ្នកជម្លៀសនៅតាមផ្លូវទេ ព្រោះតាមផ្លូវពីមណ្ឌលគិរីទៅក្រចេះ គឺមានមនុស្សតិចតួចណាស់ ។ គាត់បានជម្រាបទៅអង្គជំនុំជម្រះថា គាត់ត្រឡប់ពីភ្នំពេញវិញ បន្ទាប់ពីប្រជុំវិញតាមផ្លូវដដែល ។

## សាក្សីរំឭកអំពីការផ្តល់បទបង្ហាញរបស់ ប៉ុល ពត និង នួន ជា នៅក្នុងកិច្ចប្រជុំនៅឯក្រុងភ្នំពេញ

កិច្ចដំណើរការនីតិវិធី បានឈានទៅដល់ចំណុចដែលត្រូវពិភាក្សាគ្នាពីពេលដែលសាក្សីទៅចូលរួមប្រជុំនៅឯក្រុងភ្នំពេញ ។ លោក លីសាក់ បានសួរទៅសាក្សីថា តើលោកស្នាក់នៅទីក្រុងភ្នំពេញអស់រយៈពេលប៉ុន្មានដែរ? សៅ សារុន ចាំថាគាត់បានចូលរួមកិច្ចប្រជុំនេះចំនួន៣ថ្ងៃ និងស្នាក់នៅទីក្រុងមួយយប់ទៀត មុននឹងត្រឡប់មកមណ្ឌលគិរីវិញ ។ គាត់ចាំបានថាគាត់ស្នាក់នៅទួលមុខទន្លេបួនមុខ ប៉ុន្តែគាត់មិនចាំថាកន្លែងណាច្បាស់ឡើយ ។

សហព្រះរាជអាជ្ញាសួរឡើងវិញតាមសំណួររបស់លោក ប៊ុនឃាង ដោយសួរថាតើមានចំនួនមនុស្សប៉ុន្មាននាក់ដែលបានចូលរួមការប្រជុំនៅទីក្រុងភ្នំពេញ? សៅ សារុន ឆ្លើយម្តងទៀតថា គាត់មិនដឹងទេ តែគាត់បាននិយាយថា "មានមនុស្សមកច្រើន ពីគ្រប់ខេត្តទាំងអស់ ។" គាត់បន្ថែមទៀតថា មានអ្នកតំណាងស្រុក តំបន់ និងមានវត្តមានរបស់យោធាភូមិភាគផងដែរ ។

លោក លីសាក់ បានសួរដោយកែតម្រូវឡើងវិញនូវសំណួររបស់លោក ប៊ុនឃាង ថា តើនរណាជាអ្នកណាផ្តល់បទបង្ហាញនៅក្នុងកិច្ចប្រជុំនោះ? សាក្សីនិយាយថា គាត់ត្រឹមតែចាំបានថាមាន ប៉ុល ពត ។ លោក លីសាក់ ព្យាយាមធ្វើឲ្យគាត់មានការចងចាំឡើងវិញដូចដែលលោក ប៊ុនឃាង បានធ្វើ គឺគាត់បានអាននូវចម្លើយនៅពេលដែលសាក្សីធ្វើបទសម្ភាសជាមួយ ក.ស.ច.ស ក្នុងនោះសាក្សីបាននិយាយថា "ក្នុងការប្រជុំនេះ អ្នកបើកវគ្គមាន នួន ជា និង ប៉ុល ពត ។"

លោកប្រធាន និល ណុន បានរំឭកទៅលោក លីសាក់ ថាអត្ថបទដែលលោកលើកយកមកពិភាក្សានេះ គឺសហព្រះរាជអាជ្ញាបានសួររួចហើយ ហើយអង្គជំនុំជម្រះសុំដាស់តឿនលោក ដោយមិនអនុញ្ញាតឲ្យសួរនូវសំនួរដែលប្រចាំដែលឡើយ ។

អរគុណលោកប្រធាន។ លោក លីសាក់ បានសួរទៅសាក្សីថាតើគាត់យល់ពីគោលបំណងនៃការប្រជុំនោះទេ? លោកសាក្សី និយាយដោយភាពនឿយហត់ថា «ខ្ញុំអត់សូវយល់ពីគោលបំណងអ្វីច្បាស់លាស់ ក្នុងការប្រជុំនោះទេ។ អ្វីដែលខ្ញុំដឹង គឺការរំដោះជាតិ និងដឹកនាំប្រជាជនឲ្យធ្វើស្រែចម្ការ ដើម្បីកុំឲ្យមានភាពអត់ឃ្លាន។» ទាក់ទងនឹងការផ្តល់បទបង្ហាញរបស់ ប៉ុល ពត សាក្សីនិយាយថា គាត់ «និយាយចំនុចប្រចាំដែលៗ» ទៅលើ «ការកសាងប្រទេសជាតិ»។

ដើម្បីព្យាយាមឲ្យសាក្សីនឹកឃើញឡើងវិញម្តងទៀត លោក លីសាក់ បានអាននូវចម្លើយដកស្រង់របស់គាត់ពេលដែលធ្វើបទសម្ភាសជាមួយនឹង ក.ស.ច.ស។ លោក លីសាក់ អានថា «អ្នកទាំងពីរនាក់នេះ និយាយអំពីបញ្ហានយោបាយ រៀបចំសហករណ៍ មិនឲ្យចាយលុយ ទីផ្សារ និងវត្តអារាមត្រូវបិទ ហើយថាថ្ងៃក្រោយនឹងបើកឲ្យមានវិញ។» «វាពិតជាត្រឹមត្រូវ» សាក្សីនិយាយថា «ពួកគេនិយាយពីរឿងបិទទីផ្សារ តែនៅថ្ងៃក្រោយថានឹងបើកឲ្យមានឡើងវិញ។»

បន្ទាប់មកលោក លីសាក់ សួរថាតើគាត់មាននិយាយអំពីការបោសសម្អាតជនជាតិវៀតណាមដែរ ឬទេ?

លោក ម៉ៃខល ការណាវ៉ាស សហមេធាវីអន្តរជាតិការពារជនជាប់ចោទ អៀង សារី បានធ្វើការជំទាស់។ «ខ្ញុំដឹងថា បុរសម្នាក់នេះមានបញ្ហាខ្លះៗនឹងការចងចាំរបស់គាត់» «ប៉ុន្តែលោកដូចជាប្រើនូវសំណួរនាំមុខ ហើយវាពិតជាពុំត្រឹមត្រូវសោះ។» ដោយសារតែសាក្សីមានបញ្ហាការចងចាំនិងយល់ថា គ្រប់ចម្លើយដែលគាត់បានធ្វើនោះពិតជាសុក្រឹត្យ និងត្រឹមត្រូវ យើងមិនចាំបាច់សួរសំណួរទាំងនេះឡើយ។

សហព្រះរាជអាជ្ញាឆ្លើយតប «ខ្ញុំមិនបានសួរសំណួរណាដែលមិនមាននៅក្នុងចម្លើយរបស់សាក្សីនោះទេ» ហើយ«អំពីកិច្ចនីតិវិធីដែលខ្ញុំត្រូវគោរពតាម គឺសួរសំណួរទៅសាក្សីសិន បន្ទាប់មកឲ្យគាត់ឆ្លើយ ហើយអាននូវចម្លើយរបស់គាត់ចេញពីបទសម្ភាស»។ គាត់បានពន្យល់ថា «ដំបូងខ្ញុំចង់ឲ្យគាត់មានឱកាសឆ្លើយនឹងសំណួរសិន។»

បន្ទាប់ពីពិភាក្សាជាមួយនឹងចៅក្រមផ្សេងទៀត លោកប្រធាន និល ណុន ឆ្លើយតបថា «សេចក្តីជំទាស់ ពុំមានប្រសិទ្ធភាព។ តែទោះយ៉ាងណា ក៏តំណាងសហព្រះរាជអាជ្ញា មិនគួររំឭក ឬលើកឡើងនូវសំណួរដែលសាក្សីបានទទួលស្គាល់រួចហើយនោះទេ លោកមិនគួរតាំងសំណួរទៅគាត់ដដែលម្តងទៀត។» លោកប្រធានអង្គជំនុំជម្រះស្នើឲ្យលោក លីសាក់ តាំងសំណួរអម្បាញ់មិញសារជាថ្មីម្តងទៀត។

ចាប់ផ្តើមនូវការតាំងសំណួរទៅសាក្សី លោក លីសាក់ សួរថា «តើលោកមានចាំទេថា ប៉ុល ពត និង នួន ជា មានបាននិយាយពីការបោសសម្អាតជនជាតិវៀតណាមពីប្រទេសដែរឬទេ?»

លោក ហ្សាស្តេ ប៉ៅ មេធាវីអន្តរជាតិការពារក្តី នួន ជា ងើបឡើងធ្វើការជំទាស់ តែលោកប្រធានអង្គជំនុំជម្រះបានបញ្ឈប់គាត់ ហើយនិយាយថា បញ្ហាយើងបានពិភាក្សារួចរាល់ហើយ ។ លោកប្រធានបានប្រាប់ទៅសាក្សីឲ្យបន្តនូវចម្លើយរបស់គាត់ ។

លោក សៅ សារុន បង្ហាញនូវភាពរៀងខឹង និងអន់ចិត្ត និងនិយាយថា «ខ្ញុំមិនយល់សោះ ហេតុអ្វីបានជាខ្ញុំត្រូវឆ្លើយនឹងសំណួរទាំងនេះម្តងហើយម្តងទៀត ។ ខ្ញុំបានឆ្លើយរួចហើយទៅកាន់ សហចៅក្រមស៊ើបអង្កេត ។ ខ្ញុំសូមយោងតាមចម្លើយដែលខ្ញុំបានធ្វើជាមួយនឹងសហចៅក្រមស៊ើបអង្កេតចុះ ។» សាក្សីបន្តប្រាប់ទៅអង្គជំនុំជម្រះថា គាត់មិនធ្លាប់ឮពី «បញ្ហាវៀតណាម» អីទេ ហើយបញ្ហាហ្នឹង «វាជាបញ្ហារបស់ថ្នាក់លើ ។»

លោក លីសាក់ នៅតែប្រើប្រាស់នូវវិធីដដែល គឺគាត់បន្តអាននូវចម្លើយផ្សេងទៀតរបស់សាក្សីដែលបានធ្វើកិច្ចសម្ភាសជាមួយ ក.ស.ច.ស ។ នៅក្នុងចម្លើយនេះ សាក្សីបានប្រាប់ថា ប៉ុល ពត និង នួន ជា បានប្រាប់ទៅកម្មាភិបាលពីការដឹកជនជាតិពួកវៀតណាមតាមឡានទៅទឹកដីវៀតណាមវិញ ។

«នេះជាអ្វីដែលខ្ញុំបានឮនៅពេលនោះ...» សៅ សារុន ឆ្លើយតប «ខ្ញុំឮពីកម្មាភិបាលថា ជនជាតិវៀតណាមនៅក្នុងឡាន ហើយត្រូវបានដឹកត្រឡប់ទៅប្រទេសរបស់ពួកគេវិញ ។»

លោក លីសាក់ បានប្រកាសថា ខ្លួននៅមានសំណួរទូទៅមួយចំនួនទៀតដើម្បីសួរ ហើយសូមអរគុណទៅសាក្សី និងជម្រាបថា គាត់នឹងសួរពីបញ្ហាវៀតណាមនេះ នៅពេលក្រោយទៀត ។ លីសាក់ សួរទៅសាក្សីថា តើគាត់ចាំទេថា ប៉ុល ពត ឬ នួន ជា ធ្លាប់បាននិយាយអំពី «ខ្នាំងរបស់បក្ស» ឬ «ផែនការនៃការកសាងទំនប់ប្រឡាយទឹកទូទាំងប្រទេស» ដែរឬទេ? សាក្សីបានជម្រាបទៅអង្គជំនុំជម្រះថា គាត់អត់ដែលឮពីអ្វីដែលទាក់ទងនឹង «ខ្មាំងរបស់បក្ស» ឡើយ តែគាត់ចាំថា ប៉ុល ពត ជាអ្នកបញ្ឆាក់រឿងសាងសង់ទំនប់ប្រឡាយ ។ គាត់បន្តទៀតថា «ប្រព័ន្ធទំនប់ទឹក និងប្រឡាយត្រូវកសាងនៅតាមខេត្ត ដូច្នេះប្រជាជនអាចធ្វើស្រែ ហើយពួកគេអាចមានទឹកគ្រប់គ្រាន់ និងដើម្បីដោះស្រាយជីវភាពរបស់ប្រជាជនបាន ។ ប៉ុល ពត ជាអ្នកលើកចំណុចនៃការកសាងទំនប់ និងប្រឡាយទឹក ។»

សៅ សារុន បន្តពិភាក្សាពីរឿងគម្រោងធ្វើកសិកម្មទាំងនេះ ។ គាត់បានប្រាប់ទៅលោក លីសាក់ ថា តំបន់ជាអ្នកបង្កើត និងដាក់នូវផែនការសម្រាប់កសាងទំនប់ និងប្រឡាយ ហើយតំបន់នោះជាអ្នកប្រាប់រឿងនេះទៅគណៈឃុំ និងស្រុក ។ សាក្សីនិយាយថា ដោយឡែកសិទ្ធិអំណាចនៃការ

ស្នើឲ្យសម្រេចអ្វីមួយ មិនស្ថិតនៅចំពោះតែថ្នាក់លើតែឯងនោះទេ តែ“ប្រជាជនទាំងអស់គ្នាជាអ្នករួមគ្នា ដើម្បីសម្រេច ។”

## សាក្សីអះអាងថា ក្រុមកុលសម្ព័ន្ធដែលជឿលើការបូជាសត្វ មិនអាចបង្ហាញនូវការជឿរបស់ខ្លួនក្នុងសហករណ៍ទេ

ត្រឡប់ទៅរឿងប្រជុំនៅភ្នំពេញ ក្នុងឆ្នាំ១៩៧៥ លោក លីសាក់ សួរទៅសាក្សីថាតើគាត់ចាំបានទេថា ប៉ុល ពត បាននិយាយអ្វីខ្លះពីការបិទវត្តអារាម? សាក្សីឆ្លើយថា “ខ្ញុំគ្រាន់តែឮថា ពួកគេបិទអពោះបិទអញ្ចុះ តែវាសុទ្ធតែជាកិច្ចការរបស់អ្នកថ្នាក់លើប៉ុណ្ណោះ ។”

លោក លីសាក់ ស្នើសុំឲ្យសាក្សីរៀបរាប់ពីសាសនាដទៃទៀតរបស់ប្រជាជនដែលមាននៅក្នុងស្រុករបស់គាត់ ។ ប្រជាជនភាគច្រើននៅក្នុងស្រុកនេះ គឺជាជនជាតិភាគតិច ។ សៅ សារុន ពន្យល់ថា “អ្នកខ្លះជឿលើព្រះពុទ្ធសាសនា តែខ្លះទៀតជឿលើការសែនព្រេនខ្មោច អ្នកតា ។ វាជាការសំខាន់ណាស់សម្រាប់ជនជាតិភាគតិចក្នុងការសែនព្រេនតាមសាសនារបស់គេ ។”

សួរថាតើជនជាតិភាគតិចទាំងនេះ ត្រូវបានអនុញ្ញាតឲ្យបន្តអនុវត្តសាសនាទាំងនោះនៅអំឡុងកម្ពុជាប្រជាធិបតេយ្យដែរទេ? សៅ សារុន ឆ្លើយថា “ពុំមានការហាមឃាត់ណាមួយឡើយ ។ ជនជាតិភាគតិចទាំងនោះ អាចគោរពលើសាសនាដែលគេជឿ តែពួកគេមិនអាចរៀបចំជាអ្វីធំដុំបានឡើយ ។ ហើយតាមការពិត នៅពេលនោះប្រជាជនត្រូវបានណែនាំដែរថា កុំឲ្យខ្ជះខ្ជាយរឿងនេះពេកព្រោះពួកគេត្រូវប្រឹងប្រែងទៅលើការធ្វើស្រែចម្ការវិញ ជាជាងការធ្វើអ្វីទៅតាមសាសនានោះ ។”

សាក្សីពន្យល់ថា ពួកកុលសម្ព័ន្ធទាំងនោះជឿទៅលើវិញ្ញាណសត្វ “ឧទាហរណ៍ បន្ទាប់ពីរដូវប្រមូលកាត់រួច ពួកគេត្រូវបូជាសត្វដើម្បីថ្វាយជូនព្រះជាម្ចាស់របស់គេ ។” ពួកគេត្រូវបានណែនាំពីថ្នាក់ ស្រុក ឬឃុំឲ្យចេះ “សន្សំសំចៃ” ។ សាក្សីបានបញ្ចប់ដោយនិយាយថា ពួកគេមិនអាចខ្ជះខ្ជាយទៅលើការបូជាសត្វអស់ទាំងនេះ ស្របពេលដែលយើងត្រូវការអាហារឡើយ ។

## សាក្សី ៖ វត្តអារាម និងផ្ទះនៅមណ្ឌលគិរី “ត្រូវបានបំផ្លាញដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក”

លោក លីសាក់ សួរថាតើមានវត្តអារាមទេនៅក្នុងខេត្តមណ្ឌលគិរី? សាក្សីចាំថាមានតែវត្តបីប៉ុណ្ណោះនៅមណ្ឌលគិរី ក្នុងឆ្នាំ១៩៧៥ ។ ប៉ុន្តែបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យគោរពបូជាសាសនានៅតាមវត្តទៀតឡើយ ។ គាត់បន្ថែមថាប៉ុន្តែ “ខេត្តមណ្ឌលគិរីនេះ ត្រូវ

បានទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរ ហើយផ្ទះនិងវត្តអារាមក៏ត្រូវបានបំផ្លាញដោយសារការទម្លាក់គ្រាប់បែកផងដែរ ។»

ការពន្យល់របស់សាក្សីហាក់ដូចជាត្រូវបានច្រានចោល ដោយមិនយកចិត្តទុកដាក់ ទៅលើការនិយាយពីការទម្លាក់គ្រាប់បែក លោក លីសាក់ បានសួរថាតើនរណាជាអ្នកសម្រេចឲ្យបិទវត្តអារាមទាំងនោះ? សៅ សារុន បានឆ្លើយតបថា «គ្មាននរណាមួយពិតប្រាកដដែលសម្រេចបិទវត្តអារាមនោះទេ តែវត្តអារាមក្នុងខេត្តមណ្ឌលគិរី ត្រូវបានបំផ្លាញដោយសារតែការទម្លាក់គ្រាប់បែករបស់អាមេរិក ។» គាត់បន្ថែមថា «ម្យ៉ាងទៀត គ្មានប្រជាជនណាមួយរស់នៅទីនោះដែរ ពីព្រោះផ្ទះសម្បែងទាំងនោះត្រូវបានបំផ្លាញដោយការទម្លាក់គ្រាប់បែក ។» គាត់និយាយថា ព្រះសង្ឃក្នុងខេត្តមណ្ឌលគិរីចាប់ផ្ដើមរត់ភៀសខ្លួនក្នុងឆ្នាំ១៩៧០ ពេលដែលចាប់ផ្ដើមទម្លាក់គ្រាប់បែក ។ នៅថ្ងៃ១៧ មេសា ១៩៧៥ គ្មានព្រះសង្ឃណាគង់នៅក្នុងខេត្តមណ្ឌលគិរីនេះទៀតទេ ។ គាត់បានបញ្ជាក់ថា «អ្នកទាំងអស់នោះ រត់ភៀសខ្លួន គឺដើម្បីរស់ ។»

លោក លីសាក់ សួរថាតើប្រជាជននៅមណ្ឌលគិរីកសាងវត្តសាជាថ្មីដែរឬទេ បន្ទាប់ពីត្រូវបំផ្លាញអស់ ។ សាក្សី និយាយអត់មានទេ ។ សហព្រះរាជអាជ្ញាសួរបញ្ជាក់ «ហេតុអ្វី?» ។

មេធាវី កាណាវ៉ាស សុំជំទាស់ «ខ្ញុំមិនមានឃើញអ្វីដែលនិយាយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងភាពគ្មានសមត្ថភាព ឬការបដិសេធមិនឲ្យសង់វត្តថ្មីនោះទេ ។» គាត់បន្ថែមទៀតថា សំណួរនេះជាសំណួរនាំមុខ និងមិនត្រឹមត្រូវទេ ។

លោក លីសាក់ តបថា «សំណួរសួរថា (ហេតុអ្វី) មិនអាចគិតថាជាសំណួរនាំមុខទេ ។»

លោកប្រធាន និល ណុន ប្រកាសថា «ការជំទាស់ពុំមានប្រសិទ្ធិភាព» ។

លោក លីសាក់ សួរសំណួរដដែលទៅកាន់សាក្សី ហើយសាក្សីឆ្លើយតបថា «នោះគឺខ្ញុំមិនបានដឹងទេ ពីព្រោះវាជាការសម្រេចរបស់ថ្នាក់តំបន់ ថាតើត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែរឬទេ?» ថ្វីបើសាក្សី ជាសមាជិកនៃគណៈថ្នាក់តំបន់ក្ដី តែគាត់និយាយថាគ្មានការពិភាក្សា ឬសម្រេចចិត្តណាមួយពីថ្នាក់តំបន់អំពីការសាងសង់វត្តឡើងវិញឡើយ ។

ដោយទទួលស្គាល់ថា សាក្សីហាក់ដូចជាអស់កម្លាំង ដោយសារការសាកសួរអស់រយៈពេលបីម៉ោងមកហើយ លោកប្រធាន និល ណុន សួរទៅសាក្សីថា «តើលោកគិតថា សុខភាពរបស់លោកអាចគ្រប់គ្រាន់នឹងបន្តធ្វើសក្ខីកម្មនៅពេលថ្ងៃនេះទៀតបានឬទេ?» សាក្សីឆ្លើយដោយស្ទិតស្ទាញថា «សុខភាពខ្ញុំល្អគ្រប់គ្រាន់ អញ្ចឹងខ្ញុំអាចនៅបន្តដល់ពេលថ្ងៃនេះបាន ។»

បន្ទាប់ពីផ្ដល់ការអនុញ្ញាតដល់លោក នួន ជា ចូលរួមតាមដានសវនាការពីចម្ងាយក្នុងបន្ទប់ឃុំឃាំងសម្រាប់កិច្ចដំណើរការនីតិវិធីដែលនៅមានទៀត លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ ។

### សាក្សីនិយាយថា ការទម្លាក់គ្រាប់បែកពីមុនរហូតដល់ឆ្នាំ១៩៧៥ ធ្វើឲ្យគាត់មិនបានគ្រប់គ្រងបានយូរ

លោក លីសាក់ បានបន្តការតាំងសំណួររបស់គាត់បន្ទាប់ពីសម្រាក ដោយប្រាប់ទៅសាក្សីពីអ្វីដែលគាត់ចង់ពិភាក្សាទៅលើរឿងសហករណ៍ ហើយអ្វីសំខាន់ដែលគាត់ចាំថា ប៉ុល ពត និង នួន ជា និយាយពីអ្វីខ្លះក្នុងអំឡុងពេលប្រជុំនៅឯភ្នំពេញ ។

សាក្សីបានប្រាប់ថា "ដំបូង គាត់(ប៉ុល ពត) និយាយពីការដាក់សហករណ៍កម្រិតទាបពី៣០ទៅ៤០គ្រួសារ" ។ គាត់បាននិយាយថា បញ្ហាហូបបាយរួមគ្នាក៏ត្រូវបានលើកមកពិភាក្សាផងដែរ ។ សៅ សារុន និយាយថា ពេលដែលគាត់ទៅដល់មណ្ឌលគិរីវិញ ប្រធានតំបន់បានរៀបចំកិច្ចប្រជុំម្ដងទៀត ដោយផ្ដល់ការណែនាំយ៉ាងលម្អិតថែមទៀតពីការអនុវត្តនូវគោលនយោបាយនៃការហូបបាយរួម ។

លោក លីសាក់ បន្តទៀតដោយសួរទៅសាក្សីអំពីការពិភាក្សាក្នុងពេលប្រជុំ ការបិទផ្សារ និងការហាមឃាត់នូវការចាយលុយ ។ សៅ សារុន ឆ្លើយថា "ដូចខ្ញុំបានជម្រាបរួចហើយ" "វាគ្រាន់តែជាការប្រកាសទេ ក្រោយមកប្រជាជននឹងត្រូវបញ្ជូនត្រឡប់ទៅភ្នំពេញវិញ លុយក៏ត្រូវបើកឲ្យមានចរាចរឡើងវិញដែរ ។" លោក លីសាក់ សួរទៀតថា តើសាក្សីមានដឹងពីមូលហេតុមូលដ្ឋានណាមួយនៃការសម្រេចនេះដែរ ឬទេ? សៅ សារុន ឆ្លើយម្ដងទៀតថា "ខ្ញុំមិនអាចនឹកឃើញពីមូលហេតុនេះឡើយ ហើយវាជាកិច្ចការរបស់ថ្នាក់លើ ។"

សួរថាតើលោកអនុវត្តយុត្តិសាស្ត្របិទផ្សារ យ៉ាងដូចម្ដេចដែរ ពេលដែលលោកត្រឡប់ទៅមណ្ឌលគិរីវិញ? សាក្សីឆ្លើយទៅ លោក លីសាក់ ថាដោយសារតែការទម្លាក់គ្រាប់បែកដ៏ធ្ងន់ធ្ងរនេះបានធ្វើឲ្យប្រជាជនចាកចេញអស់ពីខេត្ត ។ ដោយសារតែប្រជាជនភៀសខ្លួនចេញអស់ ទើបទីនោះគ្មានផ្សារ ហើយគាត់បន្ថែមថា ជួនកាលគ្រាប់បែកធ្លាក់៤ទៅ៥ដងក្នុងមួយថ្ងៃ ។ "ការទម្លាក់គ្រាប់បែកបានបន្តរហូតដល់ឆ្នាំ១៩៧៥ ។ សម័យហ្នឹង មានការទម្លាក់គ្រាប់បែកស្ទើររៀងរាល់ថ្ងៃ" ។

## ក្នុងនាទីជាលេខាស្រុក សាក្សីពុំមានសិទ្ធដឹងឮនូវយុត្តិសាស្ត្រយោធា និងកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យទេ

ប្តូរទៅប្រធានបទផ្សេង លោក លីសាក់ សួរថាតើ ប៉ុល ពត ឬ នួន ជា មាននិយាយពីហេតុផលអ្វីទេនៅពេលដែលគាត់ឡើងផ្តល់បទបង្ហាញនៅឯភ្នំពេញ ពីការបញ្ជូនប្រជាជនវៀតណាមទៅទឹកដីរបស់គេវិញ ។ សាក្សីឆ្លើយតបថា «ខ្ញុំនិយាយដោយស្មោះត្រង់» «វាគឺជាបញ្ហារបស់ថ្នាក់លើ ។» ហើយគាត់បន្តឆ្លើយនូវសំណួរពីវៀតណាមដដែល ។

សាក្សីនឹកឃើញថា យោធាកងពលលេខ៩២០ បានឈរជើងក្នុងខេត្តមណ្ឌលគិរី នៅចុងឆ្នាំ ១៩៧៥ ។ ពួកគេត្រូវដាក់ពង្រាយនៅតាមកន្លែងផ្សេងៗគ្នាពាសពេញខេត្ត ហើយទីតាំងនៃការដាក់ពង្រាយនោះគឺផ្អែកទៅលើ «ស្រុក ។» សាក្សីបន្ថែមថា យោធានៃមន្ទីរកងពលតំបន់១០៥មានទីតាំងនៅស្រុកកោះញែក ដែលស្ថិតនៅ «ចម្ងាយប្រហែល២០០ម៉ែត្រពីមន្ទីរតំបន់ ។» គាត់មិនអាចនឹកឃើញថាមានទាហានប៉ុន្មាននាក់ដែលរាយនៅក្នុងស្រុកទេ ហើយគាត់បន្ថែមទៀតថា «វាជាការសម្រេចចំពោះថ្នាក់លើ ។»

ទោះជាគេមានទំនាក់ទំនងជាមួយនឹងកម្មាភិបាលកងពល៩២០ឬអត់ «គេត្រូវទាក់ទងខ្ញុំពីព្រោះពួកគេមកពីឆ្ងាយ ហើយអត់ដឹងពីភូមិសាស្ត្រច្បាស់លាស់ ។» ប៉ុន្តែគាត់មិនដែលប្រជុំអ្វីទៀងទាត់ជាមួយពួកគេទេ ។

ត្រឡប់ទៅការប្រជុំនៅភ្នំពេញម្តងទៀត លោក លីសាក់ សួរលោក សៅ សារុន ថាធ្លាប់បានឮពីការពិភាក្សាអំពីការកំណត់ ឬការសម្រិតសម្រាំង «ខ្មាំងស៊ីរូងផ្ទៃក្នុង» ដែរឬទេ? ខ្មាំង «ដែលបង្កប់ក្នុងជួរបក្ស ។» សាក្សីឆ្លើយតបថា គាត់មិនដែលឮពីការពិភាក្សាក្នុងកិច្ចប្រជុំនៅឯភ្នំពេញ ហើយមិនដែលឮប្រយោគ «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» នេះដែរ ។

## សាក្សី ពិភាក្សាពីបញ្ហារស្នេហា និងអាពាហ៍ពិពាហ៍

លោក លីសាក់ បានបន្តសួរទៅសាក្សីពីគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាប្រធានបទកំសាន្តសម្រាប់ថ្ងៃនេះ ។ ទោះជាសាក្សីបញ្ចេញនូវភាពហត់នឿយជាងមុនមួយក្នុងការសួរដេញដោលនៅថ្ងៃនេះក្តី ក៏ការពិភាក្សាពីបញ្ហារៀបអាពាហ៍ពិពាហ៍នេះហាក់ដូចជាធ្វើឲ្យគាត់រឹងមាំជាងមុនទៅវិញ ។ ចម្លើយខ្លះហាក់ដូចជាឃ្លាមួយចេញពីប្រលោម លោកជាជាងចេញពីចម្លើយរបស់អតីតលេខាស្រុកនៃរបបខ្មែរក្រហម ។

សាក្សីត្រូវបានស្នើឲ្យបកស្រាយពីគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ ។ សៅ សារុន ពន្យល់ថា «ការរៀបចំពីធីរៀបការសម្រាប់យុទ្ធជន គឺធ្វើឡើងច្រើនគូក្នុងពេលតែមួយ មានខ្លះនៅពេលផ្សេង ខ្លះមានមួយគូក្នុងពេលតែមួយ ។ ករណីភាគច្រើន យើងបានសួរទៅឪពុកម្តាយពួកគេថាតើពួកគេយល់ព្រមឲ្យរៀបការដែរអត់? តែយើងក៏បានសួរទៅកូនក្រមុំ និងកូនកំលោះ ថាតើពួកគេស្រលាញ់គ្នាដែរឬអត់ដែរ ។» សុំឲ្យសាក្សីពន្យល់ថាតើគាត់ចង់មានន័យដូចម្តេចចំពោះពាក្យ«យុទ្ធជន» ។ គាត់បានពន្យល់ថា «យុទ្ធជន» ជាមនុស្សដែលដល់ពេលកំណត់អាចរៀបការបាន ។

ទោះបីជា សាក្សីបាននិយាយពីដំបូងថា គាត់មិនដែលឮ ប៉ុល ពត និយាយពីនយោបាយនៃការរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ លោក លីសាក់ បានធ្វើឲ្យសាក្សីរំឮកឡើងវិញម្តងទៀត ។ គាត់បានអាននូវចម្លើយមួយផ្សេងទៀតពីបទសម្ភាសរបស់សាក្សីជាមួយ ក.ស.ច.ស ហើយស្រង់ពាក្យរបស់ សៅ សារុន ដែលនិយាយថា «ខ្ញុំទៅចូលរួមប្រជុំជាមួយនឹង ប៉ុល ពត ហើយគាត់និយាយថា ឲ្យរៀបការជាគូៗ កុំឲ្យពិបាកពេក ឪពុកម្តាយ ឬបង ប្អូន ក៏អាចចូលរួម ហើយកូនកំលោះ និងកូនក្រមុំត្រូវឡើងប្តេជ្ញាចិត្ត ប្រកាសប្រវត្តិរូប និងភក្តីភាពរបស់ពួកគេទៅវិញទៅមក ។»

បន្ទាប់ពីសាក្សីបានប្រាប់ទៅអង្គជំនុំជម្រះថា គាត់រក្សានូវចម្លើយទាំងនេះហើយ សៅ សារុន បានបន្តទៀតថា «ពេលដែលពួកគេរៀបការ ពួកគេត្រូវតែប្តេជ្ញាចិត្តទៅវិញទៅមក ហើយសន្យាគ្នាថានឹងស្រលាញ់គ្នាអស់មួយជីវិត ។»

ពេលដែលសួរថាតើ ប៉ុល ពត ឬមេដឹកនាំណាផ្សេងទៀតនិយាយពីការចាំបាច់នៃការបង្កើនចំនួនប្រជាជនដែរឬទេ? សាក្សីឆ្លើយតបថា «ខ្ញុំមិនបានឮពីបញ្ហានៃការបង្កើនចំនួនប្រជាជននេះទេ ប៉ុន្តែវាជារឿងធម្មតាហើយ ដែលមនុស្សរៀបការហើយ តែងតែមានកូន ដូច្នេះទើបមានការកើនឡើងនៃចំនួនប្រជាជន ។»

ដោយបន្តសួរសំណួរដ៏ជាក់លាក់មួយនូវមេរៀនជីវសាស្ត្រ សៅ សារុន បាននិយាយថា «ជាការពិតណាស់ ប្តីប្រពន្ធដែលរៀបការរួចនៅតែមិនទាន់មានកូន គឺប្រហែលដោយសារពួកគេអសមត្ថភាព ។»

លោក លីសាក់ សួរថាតើគូស្រករអនុញ្ញាតឲ្យរៀបកាទេ «បើគ្មានបញ្ហាពីអង្គការ ។» សាក្សីឆ្លើយតបថា «វាត្រូវតែមានការយល់ព្រមពីក្នុងក្រុមរបស់គេ ហើយពួកគេត្រូវរាយការណ៍ពីរឿងនេះជូនទៅកងធំរបស់គេ មុនពេលពិធីរៀបការត្រូវបានរៀបចំ» គាត់បន្តថា «អ្វីដែលសំខាន់គឺឲ្យតែពួកគេទាំងពីរស្រលាញ់គ្នាទៅវិញទៅមក ចាំបន្ទាប់មកពួកគេរាយការណ៍ទៅមេកងក្នុងក្រុមរបស់ពួកគេ ។

ប្រសិនបើមានការយល់ព្រមពីមេកងក្នុងក្រុមហើយ ក៏ត្រូវទៅសួរឪពុកម្តាយទៀតដែរ។ ប្រសិនបើឪពុកម្តាយគេយល់ព្រមហើយ ទើបយើងអាចរៀបចំដំណើរការការរៀបការនេះបាន។»

## សាក្សី ត្រូវបានតែងតាំងជាលេខាតំបន់ ពីរខែមុននឹងវៀតណាមវាយចូល

បន្ទាប់ពី ការពិភាក្សាពីរឿងរៀបអាពាហ៍ពិពាហ៍ លោក លីសាក់ ប្តូរប្រធានបទផ្សេងវិញ ដោយសួរទៅសាក្សីថាតើ ឡាំង ស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនទេ? សាក្សីនិយាយ ថា ឡាំង បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអំឡុងឆ្នាំ១៩៧៨។ សៅ សារុន បន្តទៀតថាបន្ទាប់ពីការស្លាប់របស់គាត់ សាក្សីបានជំនួសតំណែងរបស់ ឡាំង ដែលជាលេខាតំបន់១០៥ បន្ទាប់ពីការជ្រើសតាំងនៅពាក់កណ្តាលខែកញ្ញា។ (ក្រោយមកសាក្សីនិយាយថា គាត់ត្រូវបានតែងតាំងដោយ ប៉ុល ពត ឲ្យមកជំនួស ឡាំង វិញ)។ សៅ សារុន អះអាងថា គាត់បានហ៊ឹកហាត់នូវតួនាទីនេះត្រឹមតែពីរខែប៉ុណ្ណោះ រហូតដល់វៀតណាមវាយចូលក្នុងខែមករា ឆ្នាំ១៩៧៩។

លោក លីសាក់ បន្តទៅពិភាក្សាអំពីការធ្វើវិសុទ្ធកម្មនៅតាមតំបន់ នៅឆ្នាំចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ចាប់ផ្តើមសួរទៅសាក្សីថាតើលោក សៅ សារុន ស្គាល់មនុស្សឈ្មោះ ម៉ាឡា ដែរឬទេ? សាក្សីថាគាត់ស្គាល់ថា ម៉ាឡា នេះជា “ប្រធានស្រុកពេជ្រចិន្តាពីមុន។” បន្ទាប់មកសាក្សីបានប្តូរចិត្តថា ម៉ាឡា គាត់កាន់កន្លែងខ្ញុំពេលដែលខ្ញុំផ្ទេរទៅ អូរប៉ូនលើ នៅស្រុកកោះញែកក្នុងឆ្នាំ១៩៧៥។ គាត់ពន្យល់ថា គាត់ផ្ទេរទៅដោយសារតែគាត់អាចនិយាយភាសាព្នងបាន ហើយអាចនិយាយទាក់ទងជាមួយប្រជាជនដែល “ចុះមកពីតំបន់ព្រៃភ្នំដែរ។” គាត់បន្ថែមថា គាត់ត្រូវផ្ទេរត្រឡប់មកស្រុកពេជ្រចិន្តាក្នុងឆ្នាំ១៩៧៧ បន្ទាប់ពីប្រជាជនព្នងប្តូរទីលំនៅទៅតំបន់ផ្សេងទៀត។

នៅពេលដែលសួរទៅដល់ចំណុចថា តើមានអ្វីកើតឡើងចំពោះ ម៉ាឡា ពេលដែលត្រឡប់មកពេជ្រចិន្តាវិញក្នុងឆ្នាំ១៩៧៧? សៅ សារុន និយាយថា “វាជាបញ្ហារបស់ថ្នាក់លើ។ ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានហៅទៅដោយខាងតំបន់។ ខ្ញុំមិនដឹងពីមូលហេតុអ្វីទេ។ ខ្ញុំប្រឹងតែការងាររបស់ខ្ញុំ នៅក្នុងស្រុកប៉ុណ្ណោះ។»

បន្ទាប់ពីត្រូវបានសួរថាតើលោកធ្លាប់ឮពី “ការធ្វើវិសុទ្ធកម្មលើជនជាតិវៀតណាម” សាក្សីឆ្លើយដោយម៉ឺងម៉ាត់ថា “ខ្ញុំមិនដឹងអ្វីទាំងអស់ពីការធ្វើវិសុទ្ធកម្ម។ ដូចខ្ញុំបាននិយាយអញ្ចឹង ថាខ្ញុំផ្តោតតែលើការងាររបស់ខ្ញុំនៅក្នុងស្រុកប៉ុណ្ណោះ។ ខ្ញុំមិនដឹងពីកិច្ចការរបស់ថ្នាក់លើឡើយ។»

លោកប្រធាន និល ណុន បានបន្អាក់នូវកិច្ចនីតិវិធី ហើយប្រកាសសម្រាកពេលរសៀលប្រហែលជាយល់ថា ដួនកាលអារម្មណ៍របស់សាក្សីអាចកើនឡើងនូវការសម្រេចចិត្តមិនច្បាស់លាស់ក្នុងការទទួលសំណួររបស់សហព្រះរាជអាជ្ញា លីសាក់ ។

## សាក្សីបានរំឭក ពីការស្លាប់របស់បងថ្លៃពីរនាក់របស់គាត់

សាលសវនាការ និងសាលសាធារណៈកាន់តែមានភាពរស់រវើក សាក្សីបាននិយាយត្រួសៗពីការស្លាប់របស់បងថ្លៃពីរនាក់របស់គាត់ ដែលធ្វើឲ្យសាក្សីមានបញ្ហានៃការចងចាំ ការបកស្រាយដោយលម្អិតពីការស្លាប់របស់ពួកគាត់ ជាការភ្ញាក់ផ្អើល និងនឹកស្មានមិនដល់ ។

នៅពេលលោក លីសាក់ សួរទៅកាន់សាក្សីថាតើលោកស្គាល់មនុស្សឈ្មោះ ស៊ុាយ ឬអត់? សៅ សារុន ជម្រាបទៅអង្គជំនុំជម្រះថា ស៊ុាយ "បានបាញ់សម្លាប់មនុស្សដែលរាប់បញ្ចូលទាំងបងថ្លៃរបស់ខ្ញុំពីរនាក់..." គាត់បានបន្តថា "ដល់ក្រោយមក គាត់(ស៊ុាយ)ត្រូវបានគេឃើញចងកខ្លួនឯងនៅឯស្រែ ។" គាត់រៀបរាប់ថា បងថ្លៃខ្ញុំពីរនាក់ គឺ និង ដាំង ត្រូវបានបាញ់សម្លាប់ ខណៈដែលគាត់កំពុងគេង ។ តាមការចាំរបស់ សៅ សារុន "ស៊ុាយ បានបាញ់ចូលក្នុងផ្ទះអស់គ្រាប់កាំភ្លើងពីរបង់ ។ ទាំងអស់វាមាន១៨គ្រាប់ ។" "យើងមិនដឹងថាគាត់ចង់ទូទាត់រឿងអ្វីឡើយ បានមកបាញ់លើប្រជាជនដូច្នេះ" ។ សាក្សីដឹងថា ស៊ុាយ ត្រូវបានចោទប្រកាន់ថា ជាអ្នករាយការណ៍ឲ្យវៀតណាមនៅអំឡុងការប្រជុំថ្នាក់តំបន់នៅថ្ងៃមុននោះឡើយ ។ គាត់អះអាងថា គាត់មិនដឹងថាអ្វីដែលជម្រុលចិត្តឲ្យ ស៊ុាយ បាញ់សម្លាប់នូវសមាជិកគ្រួសាររបស់គាត់សោះ ។

លោក លីសាក់ បានសួរបន្តទៀតអំពីបុគ្គលិករបស់មន្ទីរ ក-១៦ ដែលរត់ទៅវៀតណាមក្នុងឆ្នាំ១៩៧៧ ។ គាត់បានសួរទៅសាក្សីថា តើប្រធានមន្ទីរ ក-១៦ នោះឈ្មោះ "តានួន" មែនទេ? សៅ សារុន ថាគាត់មិនចាំទេ ។ សង្ឃឹមថាអាចជួយរំឭកនូវការចងចាំរបស់គាត់ឡើងវិញ លោក លីសាក់ បានសួរទៅកាន់សាក្សីថា តើលោកពិតជាមិនចាំនូវឈ្មោះប្រធានមន្ទីរ ក-១៦ នេះមែនឬ? គាត់បានរត់ភៀសខ្លួនទៅវៀតណាមក្នុងឆ្នាំ១៩៧៧ ហើយត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ១៩៧៩ និងបានឡើងតំណែងជាចៅហ្វាយខេត្តក្រចេះ ។ ទោះជាមានការលំអិតអស់ទាំងនេះក៏ដោយ សាក្សីនៅតែនឹកមិនឃើញពីមនុស្សដែលឈ្មោះ នួន នោះឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយក៏លោក សៅ សារុន នៅចាំពីបុរសម្នាក់ឈ្មោះ ខាំ ភួន ផងដែរ ។ សាក្សីនិយាយថា ខាំ ភួន គឺជាសមាជិកនៃគណៈតំបន់ ប៉ុន្តែមិនអាចចាំច្បាស់នូវមុខងាររបស់គាត់ក្នុងឆ្នាំ១៩៧៧ឡើយ ។ គាត់ក៏បានចាំពីកូនរបស់ ខាំ ភួន ដែលមានឈ្មោះថា ខាន់ ដែរ ដែលត្រូវ

*បានចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ ប៉ុន្តែគាត់ប្រាកដថា ខាំ ភួន មិនត្រូវបានចាប់ខ្លួនទេក្នុងឆ្នាំ១៩៧៧ ឡើយ ។*

## *សាក្សីចាំបានថា មិនមានលេខាស្រុកណាមួយក្នុងតំបន់របស់គាត់បានគេចពីការចាប់ខ្លួន និង ស្លាប់ឡើយ*

*លោក លីសាក់ បានត្រឡប់ទៅប្រធានបទនៃឃាតកម្មរបស់បងថ្លៃគាត់ ដោយសួរទៅសាក្សីថា តើគាត់ដឹងថា អ្នកណាដែលមកជំនួសតួនាទីរបស់ ស្វាយ បន្ទាប់ពីគាត់បានចងកសម្លាប់ខ្លួនឯងដែរទេ? សៅ សារុន ថាគាត់មិនបានដឹងទេ ។ គាត់និយាយថា «ខ្ញុំភ្លេចមិនបានទេពីបញ្ហានេះ ។»*

*កាណាវ៉ាស មេធាវីអន្តរជាតិការពារក្តី អៀង សារី បានជំទាស់នៅពេលដែលសហព្រះរាជអាជ្ញាសួរទៅ សៅ សារុន ថាគាត់អាចចាំថាមានលេខាស្រុកណាខ្លះដែលបាត់ខ្លួន បានចាប់ខ្លួន ឬសម្លាប់ ។*

*លោក លីសាក់ បានពន្យល់ទៅអង្គជំនុំជម្រះថាគាត់សួរលើការ «សន្និបន្ទូវសំណួរ» ហើយគាត់ជឿជាក់ថា សាក្សីអាចមានសមត្ថភាពប្រាប់មកអង្គជំនុំជម្រះបានថា មានលេខាស្រុកណាខ្លះបាត់ខ្លួននៅអំឡុងឆ្នាំ១៩៧៧ ។»*

*បន្ទាប់ពីសុំយោបល់សន្និបៗពីចៅក្រមផ្សេងទៀត លោកប្រធានអង្គជំនុំជម្រះ និយាយថា ការជំទាស់របស់លោក កាណាវ៉ាស គ្មានប្រសិទ្ធិភាពហើយអង្គជំនុំជម្រះចង់ស្តាប់ចម្លើយពីសាក្សី ។*

*លោក លីសាក់ បានរៀបសំណួរឡើងវិញហើយសួរទៅកាន់សាក្សីថា «តើលោកចាំថាមានលេខាស្រុកណាផ្សេងពីលោក ដែលមិនត្រូវបានចាប់ខ្លួន បាត់ខ្លួន ឬក៏សម្លាប់នៅឆ្នាំ១៩៩៧ដែរឬទេ?» សៅ សារុន ឆ្លើយតបថា «អត់មានទេ ។»*

## *ប៉ុល ពត បានសួរទៅ សៅ សារុន ដោយផ្ទាល់ឲ្យជំនួសតំណែង ឡាំង ដែលជាលេខាតំបន់១០៥*

*បន្តមកទៀតលោក លីសាក់ បានសួរ សៅ សារុន ថាមានចាំ តាឡាន់ ដែលគាត់ជាមេបញ្ជាការកងវរៈសេនាតូចតំបន់១០៥ ដែរឬទេ? សាក្សីប្រាប់ថាគាត់ធ្លាប់ស្គាល់ ហើយ តាឡាន់នេះ គាត់ជាអ្នក «ត្រួតត្រាជ្រុលហួសហេតុ ។»*

*«តើលោកបានដឹងថា តាឡាំង បានឲ្យ តាឡាន់ ទៅចាប់ខ្លួន ខាំ ភួន ដែរឬទេ?» សាក្សីបានឆ្លើយថា ខ្លួនមិនបានដឹងពីរឿងនោះឡើយ ។*

សួរថាតើលោកបានដឹងអ្វីខ្លះពីការស្លាប់របស់ តាឡាំង? សៅ សារុន និយាយថា គាត់ដឹងច្បាស់ថាគាត់បានស្លាប់នៅភ្នំពេញ។ គាត់ពន្យល់ថា ប្អូនថ្លៃរបស់ តាឡាំង ឈ្មោះ ដួន បានមកប្រាប់បងប្អូនពីការស្លាប់របស់ តាឡាំង។ សាក្សីបន្តថា ភ្លាមៗបន្ទាប់ពីការស្លាប់របស់ តាឡាំង នោះ ដួន បានស្នើសុំឲ្យគាត់ទៅភ្នំពេញ។ គាត់និយាយថា ដួន ជាលេខាខាងពាណិជ្ជកម្មដែល «ទទួលខុសត្រូវលើការដឹកទំនិញពីភ្នំពេញ។» នៅពេលដែលសួរថាតើ ដួន មានឈ្មោះអ្វីផ្សេងទេ សៅ សារុន និយាយថាគាត់មិនដឹងថាគាត់មានឈ្មោះផ្សេងឬក៏អត់ឡើយ។

សង្ឃឹមថាអាចធ្វើឲ្យគាត់នឹកឃើញឡើងវិញម្តងទៀត លោក លីសាក់ បានរំឭកទៅសាក្សីនូវចម្លើយដែលគាត់បានធ្វើលើកទី៣ជាមួយនឹង ក.ស.ច.ស កន្លែងដែលគាត់និយាយថា ឈ្មោះហៅក្រៅរបស់ ដួន គឺ «ផាន យោន។»

សាក្សីឆ្លើយតប «បាទ! រំឭកអញ្ចឹងធ្វើឲ្យខ្ញុំនឹកឃើញ» «វាពិតជាត្រឹមត្រូវ។»

ត្រឡប់ទៅការស្នើសុំរបស់ ដួន ពីគាត់ទៅភ្នំពេញវិញ សៅ សារុន ពន្យល់ថា «គាត់ប្រាប់ខ្ញុំថាខ្ញុំត្រូវបានផ្ទាក់លើហៅ ហើយយើងត្រូវទៅជាមួយគ្នា។» គាត់អះអាងថា ដួន បានប្រាប់គាត់ដោយផ្ទាល់ថា ខាំ ភួន ជាអ្នកនៅពីក្រោយខ្នងក្នុងការសម្លាប់ តាឡាំង។

ពេលដែលសាក្សីនិយាយថា គាត់មិនបានដឹងពីអ្វីកើតឡើងចំពោះ ខាំ ភួន លោក លីសាក់ ក៏អាននូវចម្លើយផ្សេងទៀត។ ក្នុងចម្លើយនោះ សៅ សារុន បញ្ជាក់ថា ខាំ ភួន «បាញ់សម្លាប់ខ្លួនឯង។» ការចងចាំរបស់គាត់បាននឹកឃើញម្តងទៀត ហើយសាក្សីបានប្រាប់ទៅលោក លីសាក់ ថាចម្លើយនោះពិតជាត្រឹមត្រូវ។

លោក លីសាក់ ស្នើសុំឲ្យលោក សៅ សារុន រៀបរាប់ទៅលើដំណើរទៅភ្នំពេញ។ សាក្សីពន្យល់ថា គាត់ជិះយន្តហោះហើយទៅផ្ទះសំណាក់ ដោយមានការរៀបចំសម្រាប់ពួកយើង (ដួន និង សៅ សារុន)។ សៅ សារុន នឹកឃើញថា បន្ទាប់ពីទុករបស់របរនៅផ្ទះសំណាក់ហើយ គាត់ក៏ទៅប្រជុំជាមួយ ប៉ុល ពត នឹងបានដឹងពីការស្លាប់របស់ តាឡាំង ពិតប្រាកដ ជាពិសេសដឹងថា ខាំ ភួន បានវាយគាត់ឲ្យស្លាប់។»

លោក លីសាក់ បានសួរទៅសាក្សីថាតើគាត់មានចាំបានថាឃើញមានមេដឹកនាំធំៗណាផ្សេងទៀតទេក្នុងការប្រជុំនោះ? ពេលដែល សៅ សារុន ថាគាត់មិនបានដឹងនោះទេ។ លោក លីសាក់ បានអាននូវចម្លើយមួយផ្សេងទៀតពីសាក្សីដែលបានសម្ភាសជាមួយក.ស.ច.ស ដែលគាត់បាននិយាយថា នៅពេលដែលមកដល់ភ្នំពេញ គាត់ និង ដួន បានទៅមន្ទីររបស់ ប៉ុល ពត ផ្ទាល់ដែលនៅក្រោយវាំង កន្លែងដែលគាត់បានជួប ប៉ុល ពត សុន សេន និង នួន ជា។

មួងទៀត រំពេចនោះស្រាប់តែសាក្សីបាននឹកឃើញវិញ ហើយប្រាប់ទៅលោក លីសាក់ ថាចម្លើយក្នុងបទសម្ភាសនេះពិតជាត្រឹមត្រូវ ។ "មូលហេតុដែលខ្ញុំថា ខ្ញុំឃើញតែ ប៉ុល ពត នេះ ដោយសារតែការចងចាំរបស់ខ្ញុំវាខ្សោយ" ។

បន្ទាប់មក សៅ សារុន បានផ្តល់ព័ត៌មានលម្អិតជាងនេះពីការប្រជុំ ។ គាត់បានប្រាប់ទៅ តុលាការថា ប៉ុល ពត បានឲ្យគាត់ជំនួសតំណែង តាឡាំង ។ គាត់និយាយថា "ខ្ញុំប្រាប់គាត់ថា ខ្ញុំគ្មាន សមត្ថភាពអ្វីទេ ដោយសារខ្ញុំមិនចេះអក្សរ ខ្ញុំស្ទើរតែមិនចេះអាន និងសរសេរបានផង ។" ប៉ុន្តែ "ប៉ុល ពត ប្រាប់ខ្ញុំថាខ្ញុំអាចធ្វើបាន ហើយថាខ្ញុំអាចរៀនពីការងារទាំងនោះបាន ខ្ញុំនៅតែប្រកែក តែគាត់ចេះតែទទូចថាខ្ញុំអាចឲ្យគេជួយបាន" ។ សាក្សីចាំទៀតថា "គាត់(ប៉ុល ពត) និយាយថា ឲ្យតែ ខ្ញុំធ្វើ ខ្ញុំអាចស្នើសុំឲ្យ តាសាន ពីកងពល៩២០ជួយបាន ។" គាត់បន្ថែមថា ការប្រជុំនេះបានធ្វើអស់ ពេញមួយព្រឹក ។

លោកប្រធាន និល ណុន បានបង្អាក់លើការសួរដេញដោលដោយជម្រាបទៅអង្គជំនុំជម្រះថា វាជាពេលដែលសមល្មមនឹងសម្រាកនូវកិច្ចដំណើរការនីតិវិធីសម្រាប់ថ្ងៃនេះហើយ ។ គាត់បានសួរទៅ សាក្សីថា តើគាត់អាចបន្តត្រឡប់មកអង្គជំនុំជម្រះនៅថ្ងៃស្អែកបានដែរទេ? សាក្សីឆ្លើយដោយខ្លាំងៗ ថា "ខ្ញុំអាចមកវិញបាននៅថ្ងៃស្អែក ។"

សាក្សី សៅ សារុន បានតាំងចិត្តថានឹងត្រឡប់មកអង្គជំនុំជម្រះវិញសម្រាប់ថ្ងៃទី៣ នៃការ ផ្តល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍ ទី៧ ខែមិថុនា ឆ្នាំ២០១២ ។ ប្រសិនបើមានស្ថានភាពណាៗរារាំង ចំពោះគាត់ក្នុងការធ្វើនេះ សាក្សីបម្រុង TCW 233 នឹងត្រូវធ្វើការផ្តល់សក្ខីកម្មបន្ត ។

**-ចប់-**